Government of Western Australia
North Metropolitan Health Service

BreastScreen WA
WA's only accredited screening service

# ការធ្វើតេស្តបន្ថែមទៀត តើនេះមានន័យដូចម្តេច ?

**អ្នកត្រូវបានគេហៅមកវិញដើម្បីថតមើលដោះបន្ថែមទៀតដោយប្រើកាំរស្មីអិក្ស។ ស្ត្រីភាគច្រើនដែលត្រូវបានគេហៅមកវិញដើម្បីធ្វើតេស្តបន្ថែមទៀត មានលទ្ធផលធម្មតា (មិនមានជំងឺមហារីកដោះទេ)។**

## ហេតុអ្វីបានជាខ្ញុំត្រូវបានគេហៅមកវិញ ?

វាមិនមែនជារឿងចម្លែកទេ ដែលអ្នកត្រូវបានគេហៅមកវិញដើម្បីថតមើលដោះបន្ថែមទៀតដោយប្រើកាំរស្មីអិក្ស។ ហេតុផលទូទៅចំពោះការហៅមកវិញ រួមមាន៖

### ដង់ស៊ីតេ

ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស គឺជាការថតជាលិកាដោះរបស់អ្នកដោយប្រើកាំរស្មីអិក្ស។ ការបែងចែកជាលិកាដោះមិនស្មើគ្នា អាចមើលទៅដូចជាភាពមិនធម្មតា។ ការថតកាំរស្មីអិក្សបន្ថែមទៀត អាចជួយកំណត់តំបន់ជាលិកាដោះក្រាស់ណាមួយថាជាជាលិកាក្រពេញធម្មតា។

### ដុំសាច់ពក

ដង់ស៊ីតេរាងមូលដែលមានគែមច្បាស់លាស់ ធម្មតាគឺជាដុំសាច់ពក ឬដុំសាច់ដែលមិនបណ្តាលឱ្យមានគ្រោះកាចអ្វីឡើយ (មិនមែនជំងឺមហារីក)។ ប្រសិនបើគេមើលមិនឃើញគែមបានយ៉ាងច្បាស់ទេ ការធ្វើតេស្តបន្ថែមទៀតប្រហែលជាចាំបាច់។

### ការឡើងកំណកកាល់ស្យូម

ស្នាមអុចៗនៃជាតិកាល់ស្យូម (ការឡើងកំណក) ត្រូវបានគេមើលឃើញនៅលើរូបភាពដោះដែលថតដោយប្រើកាំរស្មីអិក្សចំពោះស្ត្រីជាច្រើន ហើយការឡើងកំណកទាំងនេះជាទូទៅគឺជារឿងធម្មតាទេ។ ទោះយ៉ាងណាក៏ដោយ ប្រជុំកំណកមិនប្រក្រតីអាចជាសញ្ញាដំបូងបំផុតនៃជំងឺមហារីក ហើយត្រូវការធ្វើតេស្តបន្ថែមទៀត។

### ស្លាកស្នាម

ការវះកាត់ពីលើកមុនៗនៅលើដោះ អាចបណ្តាលឱ្យមានស្លាកស្នាម។ ជាលិកាស្លាកស្នាមអាចធ្វើឱ្យការវិភាគកាំរស្មីអិក្សជួបការពិបាក ហើយអ្នកប្រហែលជាត្រូវការធ្វើតេស្តបន្ថែមទៀត។

### កំណាត់សម្គាល់លើស្បែក

កំណាត់សម្គាល់លើស្បែកដែលបង្ហាញនៅលើកាំរស្មីអិក្ស អាចត្រូវបានដាក់នៅលើផ្នែកដែលមានស្លាកស្នាម ប្រជ្រុយ ឬកន្លែងដែលមានរោគសញ្ញានៅក្នុងដោះ ដើម្បីជួយដល់អ្នកជំនាញផ្នែកកាំរស្មីអិក្ស សិក្សាពីកាំរស្មីអិក្ស។

## តើខ្ញុំអាចដឹងពីលទ្ធផលនៃការថតមើលដោះបន្ថែមទៀតដោយប្រើកាំរស្មីអិក្សយ៉ាងដូចម្តេច ?

BreastScreen WA នឹងទូរស័ព្ទមកអ្នក ដើម្បីប្រាប់អ្នកឱ្យដឹងពីលទ្ធផលនៃការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សរបស់អ្នក។ ការធ្វើតេស្តបន្ថែមទៀតអាចត្រូវបានណែនាំ ហើយការធ្វើតេស្តទាំងនោះនឹងអាស្រ័យលើការបង្ហាញឱ្យឃើញនៃការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស។ សូមសួរសំណួរឱ្យច្រើនតាមដែលអ្នកចូលចិត្ត ដើម្បីឱ្យអ្នកដឹងពីមូលហេតុដែលអ្នកត្រូវបានគេហៅមកវិញ។

ប្រសិនបើអ្នកត្រូវការធ្វើតេស្តបន្ថែមទៀត អ្នកនឹងត្រូវបានគេផ្តល់ជូនការណាត់ជួបមួយនៅឯមជ្ឈមណ្ឌលពិនិត្យវាយតម្លៃដោះ BreastScreen WA សម្រាប់ការធ្វើតេស្តដោះរបស់អ្នក។ សេវាកម្មនេះមិនគិតថ្លៃទេ ហើយស្ត្រីនៅតាមទីជនបទអាចមានសិទ្ធិទទួលបានជំនួយពី កម្មវិធីជំនួយការធ្វើដំណើរសម្រាប់អ្នកជំងឺ (PATS)។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីទទួលព័ត៌មានបន្ថែម។

## រូបភាពពីមុនៗ

សូមរក្សាទុករាល់រូបភាពពីការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សពីមុនៗ និងការពិនិត្យអ៊ុលត្រាសោនដោះ (ការធ្វើអេកូ) ដែលអ្នកទទួល។ រូបភាពពីមុនៗអាចជាជំនួយយ៉ាងច្រើនដល់អ្នកជំនាញផ្នែកកាំរស្មីអិក្ស ដើម្បីបង្ហាញថាផ្នែកដែលអាចជាក្តីព្រួយបារម្ភនៅលើការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សនាគ្រាបច្ចុប្បន្ន គឺជាការរកឃើញយូរអង្វែងដែលមិនបង្កទុក្ខទោស នាំឱ្យមានការព្រួយបារម្ភអ្វីឡើយ។

## តើមានការធ្វើតេស្តបន្ថែមទៀតដែលអាចចាំបាច់ឬទេ ?

ការប្រែប្រួលភាគច្រើនដែលរកឃើញដោយការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស គឺតូចពេកក្នុងការស្ទាបដឹងនៅក្នុងដោះ ហើយចាំបាច់ត្រូវធ្វើតេស្តពិសេស។

### ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស ដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែមទៀត

ដំណើរការនេះពាក់ព័ន្ធនឹងការថតពិនិត្យដោះបន្ថែមទៀតដោយប្រើកាំរស្មីអិក្ស ដែលផ្តោតលើផ្នែកដែលគ្លីនិកមានការចាប់អារម្មណ៍។

### ការថតដោះ  Tomosynthesis / ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស 3D

ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស 3D (ហៅម្យ៉ាងទៀតថាការថតដោះតាមបែបឌីជីថល tomosynthesis) ប្រើប្រូក្រាមកុំព្យូទ័រពិសេសដើម្បីបង្កើតរូបភាពដោះជាសណ្ឋាន 3D ដោយប្រើកាំរស្មីអិក្ស (ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស) ដែលថតនៅមុំផ្សេងៗគ្នា។ ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សធម្មតាបង្កើតរូបភាពដោះ 2D។

### ការពិនិត្យដោះតាមបែបវេជ្ជសាស្ត្រ

ប្រសិនបើអ្នកចង់ពិនិត្យដោះតាមក្បួនវេជ្ជសាស្ត្រ បន្ទាប់ពីរូបភាពរបស់អ្នកត្រូវបានពិនិត្យដោយអ្នកជំនាញផ្នែកកាំរស្មីអិក្សរួច គ្រូពេទ្យស្ត្រីម្នាក់នឹងធ្វើការពិនិត្យដោះរបស់អ្នកយ៉ាងហ្មត់ចត់ ហើយនិយាយជាមួយអ្នកអំពីប្រវត្តិវេជ្ជសាស្ត្ររបស់អ្នក។

### អ៊ុលត្រាសោនដោះ (ការធ្វើអេកូ)

នេះគឺជាការធ្វើតេស្តដោយប្រើរលកសំឡេង (មិនមែនវិទ្យុសកម្ម) ដើម្បីបង្ហាញជាលម្អិតបន្ថែមទៀតអំពីជាលិកាដោះ។ តួដោះត្រូវបានគេលាបបំពោកដែល ហើយឧបករណ៍ស្ទាបស្ទង់មួយត្រូវបានប្រើដើម្បីសង្កត់លើស្បែក។

### ការពិនិត្យវិភាគដោយប្រើរូបភាព

ការកាត់ជាលិកាដោះយកទៅពិនិត្យវិភាគ គឺជាកន្លែងដែលម្ជុលត្រូវបានចាក់បញ្ចូលទៅក្នុងដោះ ដើម្បីយកសំណាកជាលិកាពីផ្នែកដែលមានការចាប់អារម្មណ៍ ពីសំណាក់វេជ្ជសាស្ត្រ ដើម្បីឱ្យគេអាចយកទៅពិនិត្យវានៅក្រោមមីក្រូទស្សន៍។

អ្នកជំនាញផ្នែកកាំរស្មីអិក្សដែលអនុវត្តនីតិវិធីការងារ ប្រើការណែនាំតាមក្បួនអ៊ុលត្រាសោន ឬកាំរស្មីអិក្ស ដើម្បីធានាថាម្ជុលចាក់យកសំណាកជាលិកាគឺចាក់នៅកន្លែងត្រឹមត្រូវ។ ការប្រើថ្នាំស្ពឹកនឹងត្រូវបានប្រើនៅកន្លែងចាក់ម្ជុល។ ជាលិកាត្រូវបានពិនិត្យដោយអ្នកជំនាញផ្នែករោគសាស្ត្រម្នាក់ ហើយលទ្ធផលទាំងនេះ ជាធម្មតាអាចមានផ្តល់ជូន២៤ម៉ោងក្រោយមក។

## តង្កៀបសម្គាល់

ពេលខ្លះ បន្ទាប់ពីការថតកាំរស្មីអិក្សតាមក្បួនរួចមក ការដាក់សម្គាល់ទីតាំងជាមួយនឹងតង្កៀបលោហធាតុតូចមួយ គឺជាការចាំបាច់នៅចំកន្លែងដែលគេច្រឹបយកជាលិកាដើម្បីវិភាគ។

## តើការធ្វើតេស្តទាំងនេះអាចរកឃើញជំងឺមហារីកទាំងអស់ឬទេ ?

ជំងឺមហារីកដោះភាគច្រើននឹងត្រូវបានធ្វើរោគវិនិច្ឆ័យ ក៏ប៉ុន្តែគ្មានការធ្វើតេស្តណាមួយអាចធានាការរកឃើញនៃជំងឺមហារីកទាំងអស់បានទេ។ ជាការសំខាន់ដែលស្ត្រីទាំងអស់អនុវត្តតាមអនុសាសន៍ទាំងឡាយដែលពេទ្យបានណែនាំ។

## នៅពេលណាត់ជួបដើម្បីពិនិត្យវាយតម្លៃ

ទាំងនេះគឺជាមជ្ឈមណ្ឌលអ្នកឯកទេសមើលថែទាំគ្រប់ផ្នែក ដែលអ្នកនឹងទទួលបានការពិនិត្យវាយតម្លៃ និងការគ្រប់គ្រងដោយក្រុមពេទ្យឯកទេសដែលជំនាញផ្នែកកាំរស្មីអិក្ស អ្នកជំនាញផ្នែករោគសាស្ត្រ គិលានុបដ្ឋាក អ្នកជំនាញថតកាំរស្មីអិក្ស គ្រូពេទ្យជំងឺដោះ និងគ្រូពេទ្យវះកាត់ដោះ។

ការណាត់ជួបទាំងអស់ត្រូវបានរៀបចំឡើងនៅពេលព្រឹក។ អ្នកគួរទុកពេល**រហូតដល់ទៅ៨ម៉ោង** សម្រាប់ការពិនិត្យវាយតម្លៃពេញលេញរបស់អ្នក។ សូមជូនដំណឹងដល់បុគ្គលិកគ្លីនិក  ប្រសិនបើអ្នកត្រូវការសំបុត្រពេទ្យសម្រាប់និយោជករបស់អ្នក។

សូមយកប្រាក់មកជាប់ជាមួយសម្រាប់ការចតរថយន្ត។ ជម្រើសផ្សេងទៀត សូមទូរស័ព្ទ Transperth លេខ 13 62 13 សម្រាប់ការជ្រើសរើសយកយានដឹកជញ្ជូនសាធារណៈ។

## លទ្ធផលផ្ញើទៅវេជ្ជបណ្ឌិតរបស់អ្នក

ប្រសិនបើអ្នកមានវេជ្ជបណ្ឌិតដែលបានជ្រើសតាំង (ហើយយើងសូមលើកទឹកចិត្តឱ្យអ្នកធ្វើដូច្នេះ) BreastScreen WA នឹងជូនដំណឹងដល់វេជ្ជបណ្ឌិតទាំងនោះអំពីការណាត់ជួបរបស់អ្នកដើម្បីធ្វើតេស្តបន្ថែមទៀត។ វេជ្ជបណ្ឌិតរបស់អ្នកក៏នឹងបានទទួលដំណឹងអំពីលទ្ធផលនៃការធ្វើតេស្តវាយតម្លៃរបស់អ្នកដែរ។


## BreastScreen WA

ទូរស័ព្ទ៖ (08) 9323 6700   ទូរសារ៖ (08) 9323 6799
អ៊ីម៉ែល៖ breastscreenwa@health.wa.gov.au
សេវាកម្មជាតិបញ្ជូនបន្ត៖ www.relayservice.gov.au
សេវាកម្មបកប្រែភាសាសរសេរ និងនិយាយ៖ (TIS) 13 14 50


## មជ្ឈមណ្ឌលវាយតម្លៃ BreastScreen WA

### Royal Perth Hospital (RPH) Breast Assessment Clinic

Level 3, North Block. Wellington Street, Perth, 6000




### Sir Charles Gairdner Hospital

G Block, 1st floor, Hospital Avenue, Nedlands.



## មជ្ឈមណ្ឌលវាយតម្លៃ BreastScreen WA

## Bunbury South West Health Campus
Corner of Bussell Highway and Robertson Drive




## Fiona Stanley Hospital
**Level 1 Main Hospital, 102-118 Murdoch Drive, Murdoch Tel: (08) 6152 4125**




## Joondalup 57 Joondalup Drive, Joondalup




BreastScreen AUSTRALIA
A joint Australian, State and Territory Government Program

BEAT BREAST CANCER
HAVE A FREE X-RAY
RING: 13 20 50

LIKE US ON facebook

**www.breastscreen.health.wa.gov.au**

DEC 2022